ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

លេខ: ០៩៣/១៦ គ.ប.ជ

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែឧសភា និងទិសដៅខែមិថុនា ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៦ )

## I.ស្ថានភាពទូទៅ

នៅក្នុងខែឧសភា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) បានបំពេញតួនាទីតាមមុខងាររបស់ខ្លួនដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ដោយមានកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលជាដៃគូជាតិនិងអន្តរជាតិ។

អំពីសភាពការណ៍បទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្អែកតាមរបាយការណ៍ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ បានរកឃើញបទល្មើសជាច្រើនករណី តាមទម្រង់ផ្សេងៗដូចជាការធ្វើអាជីវកម្មផ្លូវភេទ សព្វាវកម្ម និងទេសន្តរប្រវេសន៍ស្វែងរកការងារ ការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ក្នុងចំណោមជនទេសន្តរប្រវេសន៍ ដែលកំពុងនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ ត្រូវបានរងគ្រោះជាបន្តបន្ទាប់ និងត្រូវបានបញ្ជូនមកកម្ពុជាវិញ ហើយមួយចំនួនបានត្រឡប់មកផ្ទះវិញដោយខ្លួនឯង និងខ្លះទៀតបាត់ដំណឹង ។ កត្តាទាំងអស់នេះ ជាបញ្ហាប្រឈម ដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ត្រូវរួមសហការជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិក និង អង្គភាពដែលពាក់ព័ន្ធ ត្រូវព្យាយាមបង្ការទប់ស្កាត់ និងដោះស្រាយបញ្ហារួមគ្នា ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានា សុំឲ្យមានការស្រាវជ្រាវស៊ើបអង្កេតបទល្មើស និងសិក្សាពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបំពេញតួនាទី និងភារកិច្ចយ៉ាងមមាញឹក ខិតខំប្រឹងប្រែងបន្តអនុវត្តយុទ្ធវិធី តាមផែនការសកម្មភាពជាតិ ឆ្នាំ២០១៤-២០១៨ ដើម្បីបន្តសកម្មភាពក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងជំរុញការដឹកនាំ ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការដាក់ទណ្ឌកម្ម លើជនល្មើស ។

របាយការណ៍ខាងក្រោម ជាទិន្នន័យដែលទទួលបានពីក្រុមការងារជួយជនរងគ្រោះចំនួន០១ច្បាប់ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា , ក្រុមការងារអនុវត្តន៍ច្បាប់ចំនួន០១ច្បាប់ ដែលដឹកនាំដោយ អគ្គស្នងការដ្ឋាននគរបាលជាតិ និងរាជធានី/ខេត្ត ចំនួន២៤ច្បាប់ គឺ (រាជធានីភ្នំពេញ ,ខេត្ត កោះកុង ,ព្រះសីហនុ ,កំពត ,កែប តាកែវ , កំពង់ស្ពឺ , កំពង់ឆ្នាំង ,កណ្តាល , ស្វាយរៀង ,ព្រៃវែង ,ពោធិ៍សាត់ ,ប៉ៃលិន ,បាត់ដំបង , ឧត្តរមានជ័យ ព្រះវិហារ , សៀមរាប ,កំពង់ធំ , ក្រចេះ ,ស្ទឹងត្រែង ,រតនគិរី ,មណ្ឌលគិរី ,ត្បូងឃ្មុំ និងខេត្តកំពង់ចាម) និងសកម្មភាពរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលទទួលបានលទ្ធផល ដូចខាងក្រោម ៖

## II.លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅក្នុងខែឧសភា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅការកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការ រវាងបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

### ក. ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

#### ១. ការងារបង្ការ-ទប់ស្កាត់:

#### ១.១.ការផ្សព្វផ្សាយ អប់រំ

នៅក្នុងខែឧសភា ឆ្នាំ២០១៦នេះ ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ច បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ទៅតាមគោលដៅចំនួន១,៤៤៦លើក បើប្រៀបធៀបខែមុនមានចំនួន១,៤១៤លើក មានការកើនឡើងចំនួន៣២លើក ស្មើនឹង២,២៦% និងមានមនុស្សចូលរួមសរុបចំនួន២១៨,៧០៤នាក់ បើប្រៀបធៀបខែមុនមានចំនួន១៥២,៦៦៥នាក់ មានការកើនឡើងចំនួន៦៦,០៣៩នាក់ ស្មើនឹង៤៣,២៥៧% ក្នុងនោះស្ត្រីមានចំនួន១១១,៣៥៥នាក់។ (ឧបសម្ព័ន្ធទី១)

#### ១.២.ការងារបង្ការ-ទប់ស្កាត់

យោងលើលទ្ធផលសម្រេចបាន លើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលនាយកដ្ឋានជំនាញសមត្ថកិច្ចកងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធទទួលបានលទ្ធផលសរុបៈ

- ចំនួន០៦លើក មានមនុស្សចំនួន៤៩នាក់ ស្ត្រីចំនួន៤០នាក់ និង
- ចំនួន៨៦០គោលដៅ មានមនុស្សចំនួន២,៨៧៩នាក់ ស្ត្រីចំនួន១,៩៤៩នាក់

ស្នងការដ្ឋាននគរបាល**ខេត្តស្វាយរៀង** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់ ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន០៦លើក ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន៤៩នាក់ ស្រីចំនួន៤០នាក់ ។

- ស្នងការដ្ឋាននគរបាល**ខេត្តកំពត ,កណ្តាល ,កោះកុង ,មណ្ឌលគិរី ,ក្រចេះ ,ស្ទឹងត្រែង និងខេត្តព្រះវិហារ** បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យា ហាមឃាត់ ការប្រព្រឹត្តអំពើសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា, ខារ៉ាអូខេ បានចំនួន៤៧០គោលដៅ និងមានមនុស្សចំនួន១,០៤៩នាក់ (ស្រីចំនួន៦៦០នាក់) និងបានទទួលយកក្មេងទាំងនោះឲ្យធ្វើកិច្ចសន្យា អប់រំ ណែនាំ ហើយបានអញ្ជើញអាណាព្យាបាលមកជានាយកទៅលំនៅដ្ឋានវិញ ។
- បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ទាំង២៥ រាជធានី-ខេត្ត មានចំនួន៧០គោលដៅ ក្នុងនោះអំពើជួញដូរមនុស្ស ចំនួន០៥គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចំនួន៦៥គោលដៅ ។
- ស្នងការដ្ឋាននគរបាល**ខេត្តកំពង់ចាម** បានសហការជាមួយអធិការដ្ឋាននគរបាលក្រុងកំពង់ចាម និងមន្ទីរទេសចរណ៍ខេត្ត បានចុះត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់ហាងខារ៉ាអូខេស្ថិតនៅក្នុងភូមិទី០២ សង្កាត់វាលវង្សក្រុងកំពង់ចាម សរុបចំនួន០៦កន្លែងស្មើនឹង០៦គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានរកឃើញបុគ្គលិកបម្រើហាងខារ៉ាអូខេមិនទាន់គ្រប់អាយុ គឺជាអនីតិជនចំនួន០៦នាក់ ស្រីចំនួន០២នាក់។
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តកំពង់ស្ពឺ បានសហការជាមួយកម្លាំងនគរបាលក្រុងច្បារមន បានចុះល្បាត និងត្រួតពិនិត្យនិងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួលហាងម៉ាស្សា

ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងបានអប់រំធ្វើកិច្ចសន្យាម្ចាស់ហាងមិនឲ្យទទួលយកក្មេងក្រោមអាយុ១៨ឆ្នាំ ចំនួន០៤លើក ដើម្បីចូលរួមសហការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

- ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ បានចុះល្បាតត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល ,ហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន**១៧៩**កន្លែងស្មើនឹង**១៧៩**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន**៨៣៣**នាក់ ស្រីចំនួន**៥៩១**នាក់ ។
- ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល**ខេត្តឧត្តរមានជ័យ** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន**២២**កន្លែងស្មើនឹង**២២**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន**១២០**នាក់ ស្រី**១០៥**នាក់ ។
- មន្ទីរការងារ និបណ្តុះបណ្តាលវិជ្ជាជីវៈ**ខេត្តបាត់ដំបង**
  - បានចូលរួមធ្វើវាគ្មិននៅវិទ្យុប្រជាជន FM ១០០.២៥MHz ក្នុងប្រធានបទ ស្តីពី "ការលើកកម្ពស់ ការយល់ដឹងអំពីសិទ្ធិ និងពលកម្មកុមារ ដល់យុវជន" តាមប្រកាសលេខ៣០៩ ពីល័ក្ខខ័ណ្ឌការងារក្នុងសិប្បកម្មឡឥដ្ឋបានចំនួន០៤លើក ។
  - បានចូលរួមធ្វើវាគ្មិននៅវិទ្យុប្រជាជន FM ៩២.៧0MHz ក្នុងកម្មវិធីសន្ទនាមតិពន្លឺមូលដ្ឋាន ក្រោមប្រធានបទ ស្តីពី "សុវត្ថិភាពរបស់ស្ត្រីក្នុងការងារធ្វើចំណាកស្រុក" បានចំនួន០២លើក ។
- ស្នងការដ្ឋាននគរបាល**ខេត្តសៀមរាប**
  - ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមផ្សព្វផ្សាយ ស្តីពីច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស តាមវិទ្យុបានចំនួន០៤លើក ។
  - មន្ទីរព័ត៌មានខេត្តសៀមរាប បានសហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និង អង្គភាពពាក់ព័ន្ធ ចូលរួមធ្វើជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងកម្មវិធីយើងធ្វើបាន ផ្សព្វផ្សាយអំពីការធ្វើ ចំណាកស្រុកដោយខុសច្បាប់ ការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលក្នុងខេត្តចំនួន០១លើក ។
- ស្នងការដ្ឋាននគរបាល**ខេត្តរតនគិរី** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល ,ហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន០៧កន្លែងស្មើនឹង០៧គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។
- ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល**ខេត្តក្រចេះ** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួល,ហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន**១៦៦**កន្លែងស្មើនឹង**១៦៦**គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន**៧៦៨**នាក់ ស្រីចំនួន**៥០៧**នាក់ ។
- ស្នងការដ្ឋាននគរបាល**ខេត្តកំពង់ឆ្នាំង** បានចុះល្បាត ត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់ ហាងខារ៉ាអូខេ នៅភូមិបាញ់ឆ្កោល និងភូមិត្រពាំងអន ឃុំជ្រៃបាក់ ស្រុករលាប្អៀរ ចំនួន០១កន្លែងស្មើនឹង០១គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានប្រជាពលរដ្ឋចំនួន១០៣នាក់ ស្រីចំនួន៨៣នាក់ ឧបត្ថម្ភដោយអង្គការទស្សនៈពិភពលោកប្រចាំស្រុករលាប្អៀរ ។

## ២. ការងារការពារ ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍

### ២.១ ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម

សរុបបានចំនួន១២៩នាក់ បើប្រៀបធៀបខែមុនមានចំនួន៤៤នាក់ មានការកើនឡើងចំនួន៨៥នាក់ ស្មើនឹង១៩៣,១៨% ក្នុងនោះស្ត្រី មានចំនួន២៤នាក់។

+ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បុគ្គលិកមន្ទីរសង្គមកិច្ចបានជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន២០នាក់ ស្រីចំនួន០៥នាក់ ត្រូវបានបញ្ជូនទៅមជ្ឈមណ្ឌលស្តារនីតិសម្បទា ដើម្បីទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

-បុគ្គលិកមន្ទីរសង្គមកិច្ចបានទទួលនារីរងគ្រោះដោយសារករណីសញ្ញាកម្មចំនួន០៤នាក់ ពីការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការនគរបាលខេត្ត បានបញ្ជូនទៅអង្គការក្តីសង្ឃឹម និងយុត្តិធម៌ ដើម្បីទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

+ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ បានទទួលជនអនាថាមិនស្ម័គ្រចិត្តចំនួន៨៦នាក់ពីខណ្ឌឫស្សីកែវចំនួន០២ ,ខណ្ឌទួលគោកចំនួន០៦នាក់,ខណ្ឌមានជ័យចំនួន០៥នាក់,ខណ្ឌចំការមនចំនួន២៦នាក់ ខណ្ឌសែនសុខចំនួន០១នាក់ ,ខណ្ឌពោធិ៍សែនជ័យចំនួន០១នាក់ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រុងចំនួន២៤នាក់ និងបានធ្វើការពិគ្រោះយោបល់បញ្ជូនជនរងគ្រោះឲ្យស្នាក់នៅមណ្ឌលសំចត របស់មន្ទីរសង្គមកិច្ច រាជធានីភ្នំពេញទាំង៨៦នាក់ ដើម្បីអប់រំ ណែនាំបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងសមាហរណកម្មទៅសហគមន៍វិញ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបាត់ដំបង បានសហការជាមួយអង្គការ ARM អង្គការក្តីសង្ឃឹមសម្រាប់យុត្តិធម៌ Hope for Justice និងអង្គការ HAGAR បានចុះបាន់ប្រមាណគ្រួសាររងគ្រោះដោយអំពើជួញដូរផ្លូវភេទដើម្បីទទួលសេវាថែទាំសុខភាព មានចំនួន០៧គ្រួសារ ដែលស្ថិតនៅក្រុងបាត់ដំបង ស្រុកបាណន់ ស្រុកមោងឫស្សី និងស្រុកបវេល ។

+មន្ទីរកិច្ចការនារីខេត្តសៀមរាប បានបញ្ជូននារីរងគ្រោះដោយការធ្វើចំណាកស្រុកប្រថុយប្រថានទៅប្រទេសថៃ ចំនួន០១នាក់ ទៅស្នាក់នៅមណ្ឌលអង្គការអាផ្ញីស៊ីម ដើម្បីទទួលបានការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្ទឹងត្រែង បានសហការជាមួយអង្គការទឹកចិត្តម្តាយ បានចុះសាកសួរសុខទុក្ខលើកទឹកចិត្តក្នុងការរៀបចំផែនការ គ្រួសារអតិថិជនដែលរងគ្រោះដោយបានទៅធ្វើការនៅក្រៅប្រទេស និងរៀបអាពាហ៍ពិពាហ៍ជាមួយជនជាតិចិន ត្រូវបានជនជាតិចិនធ្វើបាបចំនួន១៧នាក់(ស្រីចំនួន១២នាក់ អនីតិជន ចំនួន០៦នាក់)នៅស្រុកសៀមបូក ដោយធ្វើការប៉ាន់ប្រមាណ និងធ្វើផែនការសម្រាប់គាំទ្រគ្រួសារ ដើម្បីសមាហរណកម្មអតិថិជនមកកាន់គ្រួសារវិញ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលប្រជាជនឆ្លងដែនខុសច្បាប់ទៅប្រកបរបរលក់ឆ្នោត សុំទាន នៅប្រទេសវៀតណាមចំនួន១លើក មានចំនួន ០២គ្រួសារ មនុស្សរួម០៥នាក់ ស្រី០៣នាក់ (តាមច្រកទ្វារព្រំដែនអន្តរជាតិព្រៃវ៉ រ) សហការពីអង្គការស៊ីស៊ីភីស៊ីអា គាំទ្រដោយអង្គការសន្តិសេនា ។

**២.២ សមាហរណកម្ម និងមាតុភូមិនិវត្តន៍: ក្នុងខែឧសភា ឆ្នាំ ២០១៦**

ស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត បានទទួល និងសម្ភាសពលករទេសន្តរប្រវេសន៍ ដែលអាជ្ញាធរម៉ាឡេស៊ីបញ្ជូនមក និងអាជ្ញាធរវៀតណាមបញ្ជូនមកវិញ ក្នុងខែឧសភា ឆ្នាំ២០១៦ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។ (ឧបសម្ព័ន្ធទី៤)

**២.៣ ការងារទទួលពលករខ្មែរពីអាជ្ញាធរបរទេស:**

ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ និងខេត្តស្វាយរៀង បានទទួលការសម្ភាសពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារអន្តរជាតិបាវិត មានចំនួន៣,៣៧៩នាក់(ស្រីចំនួន១,១៣២នាក់) អនីតិជនចំនួន៣០៦នាក់ (ស្រីចំនួន១២១នាក់) ។

- ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យមានចំនួន៣,៣៥២នាក់ (ស្រីមានចំនួន១,១១៣នាក់) អនីតិជនចំនួន២៨៦នាក់ (ស្រីចំនួន១០៩នាក់) ។
- ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង មានចំនួន២៧នាក់ (ស្រីមានចំនួន១៩នាក់) អនីតិជនចំនួន២០នាក់ (ស្រីចំនួន១២នាក់) ។

-មានប្រជាពលរដ្ឋខ្មែរចំនួន០៣នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជាវិញក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

### ៣. ការងារអនុវត្តច្បាប់

**-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស**

នាយកដ្ឋានជំនាញ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដាន ស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន០៣ករណី/០៦ករណី(បើប្រៀបធៀបខែមុនថយ០៣ករណី)ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន០៦នាក់(ស្រីចំនួន០៣នាក់) សង្គ្រោះជនរងគ្រោះបានចំនួន១៣នាក់ អាយុពី១៥-១៧ឆ្នាំ ចំនួន០១នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន១២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៨នាក់ ទៅអង្គការចំនួន០៤នាក់ និងចំនួន០១នាក់ទៀត ប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ:**

សរុបចំនួន០៣ករណី/០៦ករណី ជនសង្ស័យចំនួន០៦នាក់(ស្រី០៣នាក់)ជនរងគ្រោះចំនួន១៣នាក់ អាយុពី១៥-១៧ឆ្នាំចំនួន០១នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន១២នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន០៨នាក់ អង្គការចំនួន០៤នាក់ និងចំនួន០១នាក់ ទៀតប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ ) ។

| | |
|---|---|
| -សញ្ជារកម្ម | ០១ករណី ជនសង្ស័យ ០៤នាក់ |
| -ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០១ករណី ជនសង្ស័យ ០១នាក់ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ករណី ជនសង្ស័យ ០១នាក់ |

### ៤. ការងារកិច្ចការយុត្តិធម៌

តាមទិន្នន័យដែលបានទទួលពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោស នៅក្នុងខែឧសភា ឆ្នាំ២០១៦នេះ តុលាការរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មិនទាន់បានបូកសរុបលទ្ធផលនៅឡើយ ។

### ៥. ការងារសហប្រតិបត្តិការអន្តរជាតិ

**+គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (គ្មាន)

**+ក្រុមការងារការពារជនរងគ្រោះ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)** បានចូលរួមកិច្ចប្រជុំទ្វេភាគីស្តីពីការរៀបចំសេចក្តីព្រាងផែនការសកម្មភាព MOU រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡងដ៍ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលប់បំបាត់អំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រព្រឹត្តទៅនៅទីក្រុងបាងកក ប្រទេសថៃ ។

**+ក្រុមការងារអនុវត្តន៍ច្បាប់ (អគ្គស្នងការដ្ឋាននគរបាលជាតិ)** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជូនមន្ត្រីនគរបាលជាតិ ចំនួន០៥រូប បានចូលរួមប្រជុំ និងបើកវគ្គបណ្តុះបណ្តាល ចំនួន០៥លើក ៖

• **កិច្ចប្រជុំចំនួន០៤លើក ៖**

-ប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (នៅប្រទេសថៃចំនួន០១រូប) ។

-ប្រជុំ ស្តីពីការស្រាវជ្រាវថ្នាក់ជាតិអំពើហិង្សាលើកុមារ (នៅប្រទេសចិនចំនួន០១រូប)

-ប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស និងការជួយសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរ (នៅប្រទេសថៃចំនួន០១រូប) ។

-ប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអន្តោប្រវេសន៍ខុសច្បាប់ បទល្មើសព្រហ្មទណ្ឌ ការក្លែងបន្លំតាមប្រព័ន្ធទូគមនាគមន៍ និងបទល្មើសអំពើជួញដូរមនុស្ស (នៅប្រទេសចិនចំនួន០១រូប)។

• **បើកវគ្គបណ្តុះបណ្តាលចំនួន០១លើក ៖**

-ស្តីពីការបណ្តុះបណ្តាលជំនាញស៊ើបអង្កេត សម្រាប់មន្ត្រីស៊ើបអង្កេតផ្នែករត់ពន្ធមនុស្ស ( នៅប្រទេសឥណ្ឌូនេស៊ី ចំនួន០១រូប)។

+ខេត្ត **ព្រះវិហារ ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ** បានចូលរួមកិច្ចប្រជុំជាមួយប្រទេសឡាវ ស្តីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកខុសច្បាប់ស្វែងរកការងារធ្វើនៅក្រៅប្រទេសដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឆ្លងដែន បានចំនួន០១លើក ។

+ខេត្ត **ប៉ៃលិន ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ** បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុន SOK-LEAP METREY CO. LTD ដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន០១លើក មានពលករចំនួន១៨នាក់ ស្រីចំនួន០៥នាក់ ។

**៦. ការងារពាក់ព័ន្ធនឹងកុមារ**

សកម្មភាពខិតខំប្រឹងប្រែង ក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារ ជាពិសេសកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មរបស់ គ.រ.ប.ជ/គ.ខ.ប.ជ សរុបបានចំនួន២១នាក់ ក្នុងនោះជាកុមារីចំនួន១៥នាក់ ៖

+ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានទទួលកុមារីរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃចំនួន០៥នាក់ និងបានបញ្ជូនទៅអង្គការកម្ពុជាដើម្បីស្ត្រីមានវិបត្តិ ដើម្បីទទួលសេវាស្នាក់នៅ អប់រំចំណេះដឹង និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ។

-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ បានទទួលកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ចំនួន១០នាក់ ក្នុងនោះទទួលបានពីអង្គការថែទាំអន្តរជាតិស៊ីធីក័ញចំនួន០១នាក់ អង្គការគ្រួសារថ្មី០១នាក់ អង្គការហោប្ហា០១នាក់ អង្គការទឹកចិត្តម្តាយ០១នាក់ពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន០៣នាក់ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ ០៣នាក់ ដើម្បីទទួលសេវាស្នាក់នៅ អប់រំចំណេះដឹង និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ បានទទួលកុមាររងគ្រោះដោយការធ្វើអាជីវកម្មផ្លូវភេទ ០៩នាក់ (កុមារី) ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស បានទំនាក់ទំនងបញ្ជូនពួកគេឲ្យទៅទទួលសេវាថែទាំព្យាបាលជំនួស នៅអង្គការមេត្រីអន្តរជាតិ ចំនួន០៦នាក់ និងអង្គការកម្ពុជាដើម្បីជួយដល់ស្ត្រីមានវិបត្តិ០៣នាក់ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល បានសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ទទួលកុមារីរងគ្រោះដោយអំពើជួញដូរមនុស្ស ពីអង្គការមេត្រីអន្តរជាតិ ចំនួន០៣នាក់ទៅកាន់ប្រទេសវៀតណាមវិញតាមច្រកទ្វារក្អមសំណរខេត្តកណ្តាល ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តសៀមរាប បានចុះប៉ាន់ប្រមាណ កុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយអង្គការក្តីសង្ឃឹម និងយុត្តិធម៌ ចំនួន០១នាក់នៅភូមិត្បែងលិច ឃុំត្បែង ស្រុកបន្ទាយស្រី ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលប្រជាជនឆ្លងដែនខុសច្បាប់ទៅប្រកបមុខរបរលក់ឆ្នោត សុំទាន និងធ្វើការកសិដ្ឋាន នៅប្រទេសវៀតណាមចំនួន០១លើក មានចំនួន០២គ្រួសារ សរុបកុមារាចំនួន០៥នាក់ កុមារីចំនួន០៣នាក់ (តាមច្រកទ្វារអន្តរជាតិបាវិត) ។

**៧. ការងារទេសន្តរប្រវេសន៍**

○ តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើការសម្ភាសពលករខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍បានចំនួន៧០គូ និងបានសាកសួរសុខទុក្ខនារីខ្មែរ ដែលបានរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបានចំនួន២០នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ព្រមទាំងបានសម្ភាសពលករ ពលការិនីរងគ្រោះចំនួន៣១នាក់ក្នុងនោះមាន ៖

-មកពីប្រទេសម៉ាឡេស៊ីចំនួន០៩នាក់ និងមកពីប្រទេសថៃ២២នាក់(តាមការសម្ភាសទៅតាមក្រុមហ៊ុនចំនួន១៣នាក់ និងតាមរយៈមេខ្យល់ចំនួន០៦នាក់ ១២នាក់ទៀតទៅដោយខ្លួនឯង ។

តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើនៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែឧសភាឆ្នាំ២០១៦សរុបបានចំនួន២៩០,៧២៤នាក់(ស្រីចំនួន១២៨,៩៦៧នាក់) អនីតិជន មានចំនួន៥,៧៧៤នាក់ (ស្រីចំនួន២,២៤០នាក់) ក្នុងនោះស្របច្បាប់ចំនួន១៥៤,១២៧នាក់(ស្រីចំនួន៧០,៦១៧នាក់) និងអនីតិជនចំនួន៦៥៦នាក់ (ស្រីចំនួន២៨១នាក់) មិនស្របច្បាប់ចំនួន១៣៦,៥៩៧នាក់ (ស្រីចំនួន៥៨,៣៥០នាក់) និងអនីតិជនចំនួន៥,១១៨នាក់(ស្រីចំនួន១,៩៥៩នាក់) ។

## ខ.ការងារដឹកនាំសម្របសម្រួល

ការងារដឹកនាំសម្របសម្រួលសរុបរួមបានចំនួន៦៥លើក ក្នុងខែឧសភា ឆ្នាំ២០១៦ ដែលធ្វើឡើងដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងគណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ។ (**ឧបសម្ព័ន្ធទី៧**)

**+សកម្មភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីបច្ចុប្បន្នភាពការងារ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) នៅទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរក្រសួងបូកសរុបរបាយការណ៍ត្រីមាសទី១ របស់គ.ជ.ប.ជ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅ ទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការដៃគូសហប្រតិបត្តិការ ស្តីពីការពិនិត្យកែសម្រួលសេចក្តីព្រាង កិច្ចព្រមព្រៀងរវាងកម្ពុជា-ចិន ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ ។
- បានអញ្ជើញជាគណៈអធិបតីក្នុងមិទ្ទិញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏**ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ។
- បានអញ្ជើញចូលរួមប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការកែសម្រួលអនុស្សរណៈរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីបង្កើត និងដំណើរការគណៈកម្មការរួមកម្ពុជា-អាមេរិក សម្រាប់ការធ្វើមាតុភូមិ

និវត្តន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ។

- ក្នុងនាមជាប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ បានដឹកនាំកិច្ច ប្រជុំផ្សព្វផ្សាយប្រកាស ស្តីពីការកែសម្រួលសមាសភាពក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពបញ្ជ្រាប យេនឌ័រ នៅទីស្តីការក្រសួងមហាផ្ទៃ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ។

## ឃ. ការលើកកម្ពស់សមត្ថភាព

### ១.ការបណ្តុះបណ្តាល

+ ខេត្តស្វាយរៀង

-ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីកិច្ចការពារកុមារ និងការធ្វើចំណាកស្រុក ដល់ក្រុមប្រឹក្សាឃុំ មេភូមិ និងយុវជននៅឃុំគោកព្រីង ឃុំតាសួស ស្រុកស្វាយជ្រុំ ចំនួន០២វគ្គ មានអ្នកចូលរួមចំនួន៦០នាក់ ស្រីចំនួន១៨នាក់ មានការឧបត្ថមគាំទ្រដោយអង្គការឆាលហ្វានកម្ពុជាខេត្ត ។

+ខេត្តកណ្តាល មន្ទីរកិច្ចការនារីបានបើកវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្ត្រក្នុងការសម្របសម្រួលការបញ្ជ្រាបយេនឌ័រការប្រយុទ្ធប្រឆាំងជួញដូរមនុស្ស មានអ្នកចូលរួមចំនួន៣៧នាក់ ស្រីចំនួន៣៦នាក់ ។

### ២. សិក្ខាសាលា (គ្មាន)

## III. ការវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង ក្នុងខែឧសភា ឆ្នាំ២០១៦នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី ភារកិច្ចរួម ជាស្រេច។

២. បានដាក់ចុះផែនការសកម្មភាពជាតិរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រាប់រយៈ ពេល៥ ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារទាំង៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ។

៤.បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

### ខ.ចំណុចសេសសល់ និងភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ក្រុមការងារអន្តរក្រសួងស្ថាប័ន ព្រមទាំងលេខាធិការដ្ឋានរាជធានី-ខេត្ត មួយចំនួនមិនទាន់ផ្ញើរបាយការណ៍ប្រចាំខែបានតាមការកំណត់ របស់ គ.ជ.ប.ជ នៅឡើយ ។
- ត្រូវពង្រឹងសមត្ថភាពដល់មន្ត្រីបំពេញការងារបន្ថែមទៀត ដោយមូលហេតុមានការផ្លាស់ប្តូរ សមាសភាព និងការរៀបចំជាថ្មីនូវរចនាសម្ព័ន្ធតាមបណ្តាថ្នាក់ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយ៉ាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ហើយចំណេះដឹងនិងការអប់រំ របស់ពួកគាត់នៅមានកម្រិតដូច្នេះទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ ។
- អង្គការជាតិ និងអន្តរជាតិមួយចំនួន នៅមិនទាន់ចូលរួមពេញលេញក្នុងការអនុវត្តយន្តការ និងសកម្មភាពរួមនេះ ហើយបានធ្វើសកម្មភាពដោយឡែក ដែលមិនឆ្លើយតបនឹងគោលដៅ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

## IV.ទិសដៅសម្រាប់ខែមិថុនា ឆ្នាំ ២០១៦

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និង គោលការណ៍ណែនាំរបស់រាជ រដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍ ។

២. បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ ពាក់កណ្តាលអាណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨ ។

៤. រៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមបណ្តាក្រសួង មន្ទីរ ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញការអនុវត្តបន្ត ។

៥. ត្រៀមសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៦. ធ្វើការស្រាវជ្រាវ អំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុងនិងក្រៅប្រទេស និងស្វែងយល់ពីកត្តារុញច្រាន និងអូសទាញ ដើម្បីរៀបចំផែនការបង្ការទប់ស្កាត់ ។

៧. ត្រៀមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាង កិច្ចព្រមព្រៀង ដែលបានឯកភាពគ្នាជាគោលការណ៍រួចហើយ កាលពីជំនួប នៅប្រទេសចិន នាខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ត្រៀមពិនិត្យ កិច្ចព្រមព្រៀង ទ្វេភាគី កម្ពុជា-ឥណ្ឌា តាមការស្នើសុំរបស់ រដ្ឋាភិបាលឥណ្ឌា ។

៩. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល(ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ដើម្បីចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និយោជក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ប្រកបដោយសមធម៌ ។

១០. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

១១. ជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ទៅតាមមុខសញ្ញានៃក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

១២. សម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែក គ្រប់វិស័យ និងរវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដើម្បីអនុវត្ត យុទ្ធសាស្ត្រ ដែលបានគ្រោងទុកក្នុងផែនការជាតិ ផែនការរបស់ក្រុមការងារទាំងប្រាំមួយ និងផែនការរាជធានី/ខេត្ត ។

១៣. គាំទ្រ និងពង្រឹងសមត្ថភាព របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

១៤. បន្តការងារផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការ យល់ដឹងជាសកល អំពីអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ
"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"
-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## ការចាប់ផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលខេត្តកំពត ,ស្វាយរៀង និងខេត្តកំពង់ចាម បានធ្វើការផ្សព្វផ្សាយស្តីពីច្បាប់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ភូមិ/ឃុំ មានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 319 លើក | 15,130 នាក់ | 8,094 នាក់ |
| 2 | កណ្តាល | ក្រុមការងារថ្នាក់ស្រុកបានចូលរួមផ្សព្វផ្សាយស្តីពីការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព ជូនដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 3 លើក | 104 នាក់ | 68 នាក់ |
| | | មន្ទីរអប់រំយុវជន និងកីឡាខេត្តបានបញ្ជ្រាបការផ្សព្វផ្សាយ ការទប់ស្កាត់ការជួញដូរមនុស្ស ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅស្រុកពញាឮ និងស្រុកលើកដែក ។ | មន្ទីរអប់រំយុវជន និងកីឡា | 1 លើក | 876 នាក់ | 446 នាក់ |
| | | ក្រុមការងារថ្នាក់ស្រុកបានចូលរួមផ្សព្វផ្សាយ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាក់ស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ តាមរយៈវេទិកាសាធារណៈស្តីពីផែនការអនុវត្តន៍គោលនយោបាយ ភូមិ /ឃុំ មានសុវត្ថិភាព ។ | ស្នងការដ្ឋាននគរបាលខេត្ត | 28 លើក | 1,914 នាក់ | 1,033 នាក់ |
| 3 | កំពង់ស្ពឺ | ការិយាល័យជំនាញបានសហការជាមួយកម្លាំងអធិការដ្ឋាននគបាលស្រុកគងពិសី ស្រុកថ្ពង់ និងអាជ្ញាធរមូលដ្ឋាន ចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 3 លើក | 538 នាក់ | 274 នាក់ |
| 4 | កំពត | ថ្នាក់ដឹកនាំខេត្ត សហការជាមួយមន្ទីរកិច្ចការនារី មន្ទីរអង្គភាពពាក់ព័ន្ធក្នុងក្រុមការងារទាំង ៦ និងក្រុងស្រុក បានធ្វើការបញ្ជ្រាបផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្រី និងកុមារ ការធ្វើចំណាក់ស្រុកប្រកបដោយសុវត្ថិភាព ក្នុងវេទិការ សាធារណៈនៅតាមស្រុកបាន ( ស្រុកអង្គជ័យ ស្រុកដងទង់ ) ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង មន្ទីរកិច្ចការនារីខេត្ត | 2 លើក | 119 នាក់ | 48 នាក់ |
| 5 | ត្បូងឃ្មុំ | មន្ទីរកិច្ចការនារីស្រុកបានសហការជាមួយ គ ក ស ក និង គ ក ន កបានធ្វើការផ្សព្វផ្សាយ ការធ្វើចំណាក់ស្រុក និងការទប់ស្កាត់អំពើជួញដូរមនុស្ស ។ | មន្ទីរកិច្ចការនារីខេត្ត | 8 លើក | 350 នាក់ | 258 នាក់ |
| | | លេខាធិការដ្ឋានខេត្តបានធ្វើវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់ពីចំណាក់ស្រុកប្រកបដោយសុវត្ថិភាពនិងការជួញដូរមនុស្សដោយខុសច្បាប់ នៅក្រុងស្រុក | លេខាធិការដ្ឋាន គ.ខ.ប.ជ | 7 លើក | 815 នាក់ | 711 នាក់ |
| | | មន្ទីរអប់រំ យុវជន និងកីឡា បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់ការជួញដូរកុមារ នៅឃុំ រកាខ្នុរ ស្រុកក្រូចឆ្មា ។ | មន្ទីរអប់រំ យុវជន និងកីឡា | 1 លើក | 80 នាក់ | 50 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
